

# ព្រះវិហារក្នុងប្រទេសហ្វាំងឡង់

# សូមស្វាគមន៍!









## ព្រះវិហារ ចំពោះជីវិតប្រចាំថ្ងៃ និងក្នុងការប្រារព្ធពិធីបុណ្យ

ព្រះយេស៊ូវយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា "ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅស្ថានសួគ៌ ទាំងនៅលើផែនដី ។ ដូច្នេះ ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវក័ ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា ។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក" ។
ម៉ាថាយជំពូកទី២៨ ១៨-២០

## ក្រុមជំនុំ

ក្រុមជំនុំគ្រីស្ទបរិសទ័ គឺជាសហគមន៍មួយនៃគ្រីស្ទបរិសទ័ ។ ក្រុមជំនុំធ្វើសកម្មភាពតាម
តំបន់ដាច់ដោយឡែកពីគ្នា ប៉ុន្តែជាផ្នែកមួយ នៃព្រះវិហារគ្រីស្ទបរិសទ័នៅទូទាំង
ពិភពលោក ។ ព្រះវិហារគ្រីស្ទបរិសទ័បើកចំហរសំរាប់គ្រប់គ្នាទាំងអស់ ហើយលោក
អ្នកត្រូវបានស្វាគមន៍អោយចូលរួមក្នុងសកម្មភាពនេះ ។ អ្នកមិនចាំបាច់ ជា
គ្រីស្ទបរិសទ័ទេ ក្នុងការចូលរួមសកម្មភាពព្រះវិហារ ឬក៏ទទួលនូវការគាំទ្រ។
នៅឯព្រះវិហារ លោកអ្នកអាចបង្កើតសម្ពន្ធ័ភាពមិត្តភក្រ្ត័ ហើយប្រហែលជាអាចចូលរួម
ក្នុងការងារស្មគ្រ័ចិត្តខ្លះផងដែរ ។

បុគ្គលម្នាក់ក្លាយជាសមាជិកព្រះវិហារគ្រីស្ទបរិសទ័តាមរយៈពិធីជ្រមុជទឹក ។ ពិធីជ្រមុជ
ទឹកជាពិធីបរិសុទ្ធនៃព្រះវិហារ។ ព្រះយេស៊ូវ ព្រះអង្គផ្ទាល់ បានបញ្ជាក់ពីពិធីជ្រមុជទឹក
ទៅដល់សាវក័របស់ទ្រង់ ។

ឪពុកម្តាយធម៌ ឬអ្នកឧបត្ថម្ភដល់ពិធីជ្រមុជទឹក គឺជាគ្រីស្ទបរិសទ័ដែលមានភារកិច្ចគាំទ្រ
ដល់ការចិញ្ចឹមបីបាច់ខាងព្រលឹងវិញ្ញាណចំពោះអ្នកជ្រមុជទឹក ហើយអធិស្ឋានដល់
គាត់ ។ ប្រសិនបើលោកអ្នកចង់ក្លាយទៅជាសមាជិកព្រះវិហារវយ័ជំទង់ម្នាក់ អ្នកត្រូវ
តែចូលរួមក្នុងការរៀនសូត្រសំរាប់មនុស្សវយ័ជំទង់ ។ បន្ទាប់ពីបញ្ចប់ អ្នកនឹងត្រូវបញ្ជាក់
ហើយទទួលការជ្រមុជទឹក បើសិនជាអ្នក មិនបានទទួលនូវការជ្រមុជទឹកពីមុនមកទេ ។
អំឡុងពេលសិក្សា សិស្សរៀនអំពីព្រះគម្ពីរ សៀវភៅគ្រីស្ទបរិសទ័បរិសុទ្ធ ហើយនឹង
រៀនអោយស្គាល់ពីព្រះ។ វគ្គសិក្សាក៏នឹងបង្រៀន ផងដែរអំពីចំណេះដឹងពីជ្រមុជទឹក
ដែលប្រហែលជាចូលរួមដោយយុវជន ។ ក្រោយពីចូលរួមក្នុងវគ្គសិក្សា អ្នកនឹងត្រូវ
បញ្ជាក់ទទួលស្គាល់ដោយព្រះវិហារ ។ ការអះអាង មានន័យថា អ្នកសារភាពអំពី
ជំនឿរបស់អ្នកជាគ្រីស្តបរិសទ័ម្នាក់ ខណៈពេលដែលព្រះ ពង្រឹងសេចក្តីជំនឿរបស់អ្នក។
អ្នកគួរតែចូលរួមក្នុងវគ្គសិក្សា បើទោះបីជាមិនចង់ក្លាយជាសមាជិកព្រះវិហារក៏ដោយ
ចុះ ។ ជាទូទៅយុវជនហ្វាំងឡង់ តែងតែឆ្លងកាត់វគ្គនេះចន្លោះពី អាយុ១៤-១៦ឆ្នាំ ។

   

ព្រះជាម្ចាស់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ហេតុនេះហើយបានជាព្រះអង្គប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គមកដើម្បី អោយអស់អ្នកដែលជឿលើព្រះបុត្រាមានជីវិតអស់កល្បជានិច្ច គឺមិនអោយគេវិនាសឡើយ ។ យូហានជំពូកទី៣ ខ១៦

## គ្រីស្ទបរិសទ៍ជឿលើព្រះតែមួយ

គ្រប់គ្រីស្ទបរិសទ៍ចាត់ទុកព្រះជាអ្នកបង្កើត អ្នកសង្គ្រោះ និងអ្នកការពារពិភពលោក។ ព្រះគឺជាសេចក្តីស្រឡាញ់ ហើយរាល់មនុស្សទាំងអស់មានភាពស្មើគ្នានៅក្នុងព្រះនេត្រព្រះអង្គ ។ ព្រះបានបង្ហាញព្រះកាយព្រះអង្គផ្ទាល់ទៅដល់មនុស្សក្នុងពិភពលោកដែលទ្រង់បង្កើត ហើយតាមរយៈសំណេរបរិសុទ្ធនៃព្រះគម្ពីរ ។ ព្រះទ្រង់ជាគ្រប់យ៉ាង ហើយគ្រប់គ្នាគួរតែអធិស្ឋានដល់ទ្រង់ ។ ព្រះដឹងពីការគិតរបស់យើង ហើយដឹងពីយើងម្នាក់ៗយ៉ាងច្បាស់ប្រាកដ ។ ព្រះបានបញ្ជូនព្រះយេស៊ូវដែលជាអ្នកសង្គ្រោះពិភពលោក ដោយព្រះគម្ពីរ បញ្ជាក់ប្រាប់យើងអំពីទ្រង់យ៉ាងច្បាស់ ។ ព្រះយេស៊ូវ បើកផ្លូវសំរាប់យើងទៅកាន់ព្រះ ដោយរំលោះអំពើបាបរបស់យើង ។ ព្រះយេស៊ូវគឺជាបុគ្គលប្រវត្តិសាស្ត្រ និងជាព្រះ ។ ទ្រង់ត្រូវកាត់ទោសក្នុងនាមជាជនស្លូតត្រង់ ប៉ុន្តែបីថ្ងៃក្រោយមក ទ្រង់រួចពីសេចក្តីស្លាប់ ។ គ្រីស្ទបរិសទ៍ គឺជាមនុស្សទទួលព្រះយេស៊ូវធ្វើជាព្រះអង្គម្ចាស់សង្គ្រោះ នឹងទទួលជីវិតអស់កល្ប បន្ទាប់ពីបាត់បង់ជីវិត។ ចំពោះគ្រីស្ទបរិសទ៍ ឈើឆ្កាងជាសញ្ញានៃជយ័ជំនះ ដែលបញ្ជាក់ពីសេចក្តីស្លាប់ និងការរស់ឡើងវិញនៃព្រះយេស៊ូវ ។

ព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងទៅកាន់ព្រះគ្រីស្ទ ហើយទៅកាន់សេចក្តីទុកចិត្តនៃសេចក្តីសន្យារបស់ព្រះ ។ ព្រះវិញ្ញាណបរិសុទ្ធបង្កើនជំនឿក្នុងព្រះ ហើយជួយមនុស្សអោយស្រឡាញ់ព្រះ និងអ្នកជិតខាងរបស់ពួកគេ ។

## ព្រះវិហារគឺសំរាប់អ្នកនិងគ្រួសារអ្នក

ព្រះវិហារគឺនៅជាមួយអ្នកគ្រប់ដំណាក់កាលផ្សេងគ្នានៃជីវិតរបស់អ្នក
ផ្នែកមួយក្នុងចំណោមលក្ខណៈពិសេសនៃព្រះវិហារ Lutheran របស់ហ្វាំងឡង់
គឺការបណ្តុះបណ្តាលល្អ និងជំនាញទូលំទូលាយរបស់អ្នកធ្វើការ ។ នៅក្នុងព្រះវិហារ
អ្នកអាចស្វែងរកជំនួយផ្សេងៗបាន ជាឧទាហរណ៍ បុគ្គលិកធ្វើការជាមួយកុមារ គ្រួសារ
យុវជន និង diakonia តន្ត្រីករ និងគ្រូគង្វាល ក៏ដូចជាអ្នកជំនាញក្នុងវិស័យផ្សេងៗទៀត
ជាដើម ។

កុមារ និងកុមារភាព ត្រូវផ្តល់តម្លៃខ្ពស់ក្នុងព្រះវិហារ ។ សំរាប់កុមារ មានសកម្មភាព
ជាច្រើនពិសេសសំរាប់ពួកគេ ដូចជាការថ្វាយ បង្គំ និងសាលាថ្ងៃអាទិត្យ ក្លឹប ការដើរ
កំសាន្ត និងបោះជំរុំ ។

ការងារយុវជនរបស់ព្រះវិហារគឺផ្តល់ដល់យុវជននូវការបង្រៀនពីព្រះគម្ពីរ ក្លឹប
កម្មវិធីពិសេសពេលល្ងាច ល្បែងកំសាន្តសប្បាយពេលល្ងាច ដំណើរកំសាន្ត បោះជំរុំ និង
តន្ត្រី ។

គ្រីស្ទបរិសទ័ បំរើមនុស្សតាមគ្រប់មធ្យោបាយ ។ ទាំងនេះគឺអ្វីដែលហៅថា
deacon (ជាភាសាអង់គ្លេស) ឬ diakonia (ជាភាសាហ្វាំងឡង់)។
អ្នកអាចសាកសួរយោបល់ពីការងារ diakonia នូវគ្រប់កាលៈទេសៈ ។
បុគ្គលិក បំរើការងារនៅព្រះវិហារ ធ្វើការងារជាគ្រូគង្វាលផងដែរ ។
កិច្ចសន្ទនារវាងអ្នកនិងគ្រូគង្វាល ត្រូវចាត់ទុកជារឿងសម្ងាត់ផ្ទាល់ខ្លួន
ដូចជាទាក់ទិននឹងសំណួរអំពី ជំនឿ ឬបញ្ហាផ្សេងទៀត ទាក់ទិននឹងជីវិត ។
ក្រុមប្រឹក្សាយោបល់លើបញ្ហាគ្រួសារ ផ្តល់ជូននូវការពិភាក្សាពីអាពាហ៍ពិពាហ៍
និងបញ្ហាទាក់ទងនឹងគ្រួសារ ។ នៅតាមមន្ទីរពេទ្យខ្លះ វិទ្យាស្ថានសិក្សា ពន្ធនាគារ
និងបន្ទាយកងទព័ មានអ្នកធ្វើការក្នុងព្រះវិហារដែលអាចជជែក និងអធិស្ឋាន ។
មានពិធីបុណ្យជាច្រើនបែបរបស់ព្រះវិហារ ដែលអ្នកអាចអនុវត្តសេចក្តីជំនឿរបស់អ្នក
ដោយផ្ទាល់ជាមួយមនុស្សផ្សេងទៀត ។ សកម្មភាពព្រះវិហារកណ្តាលគឺការថ្វាយបង្គំព្រះ
ថ្ងៃអាទិត្យ ។ លើសពីនេះទៅទៀត ក្រុមជំនុំបានអនុវត្តយ៉ាងទូលំទូលាយនូវ សកម្មភាព
ផ្សេងៗដូចជាការពិភាក្សានិងសិក្សាជាក្រុម សកម្មភាពតន្ត្រី ការធ្វើដំណើរកំសាន្ត និង
សមាធិ ។ អ្នកអាចចូលរួម ក្នុង ការងារស្មគ្រ័ចិត្ត ឬប្រហែលជាអាចជួយបំរើក្នុងការថ្វាយ
បង្គំ ។ មានការងារជាច្រើនដែលអ្នកអាចចូលរួមជួយបាន ។

## ការថ្វាយបង្គំព្រះថ្ងៃអាទិត្យ

កម្មវិធីថ្វាយបង្គំព្រះអង្គថ្ងៃអាទិត្យ អញ្ជើញគ្រប់គ្រីស្ទបរិសទ័ទាំងអស់អោយមកជួបជុំគ្នា ។ ជាទូទៅកម្មវិធីសំខាន់គឺពេលព្រឹកថ្ងៃអាទិត្យវេលាម៉ោង១០ ។ គ្រួសារទាំងមូលអាចចូលរួមក្នុងកម្មវិធីនេះ ។ ពិធីជួបជុំ ដែលហៅផងដែរថា Messu រាប់ទាំងជំនួបបរិសុទ្ធ ដែលជាពិធីមួយក្នុងចំណោមពិធីសំខាន់ពីរ នៃព្រះវិហារ Lutheran។ នៅក្នុងការជួបជុំ មនុស្សទទួលបាននូវការអត់ទោស។ ព្រះ ទ្រង់ បំរើរាស្ត្រព្រះអង្គ ជាមួយព្រះបន្ទូល ។ សេចក្ដីអធិស្ឋាន សេចក្ដីសារភាពកំហុស អានព្រះគម្ពីរនិងសរសើរតម្កើង ទាំងអស់របស់ក្រុមជំនុំគឺមានទំនាក់ទំនងគ្នា ។

## ព្រះវិហារ និងសង្គម

ព្រះវិហារបានដើរតួនាទីយ៉ាងសំខាន់ ក្នុងប្រវត្តិសាស្ត្រហ្វាំងឡង់តាំងពីសតវត្សទី១២មកម្ល៉េះ ។ ភាសាសរសេររបស់ហ្វាំងឡង់ ត្រូវបានអភិវឌ្ឍន៍ តាមរយៈព្រះវិហារ ដូចជាការបង្កើតប្រពន្ធ័អប់រំ សេវាថែទាំសុខភាព និងសេវាសង្គម ។ ច្បាប់ហ្វាំងឡង់ផ្អែកតាមគោលការណ៍ព្រះគម្ពីរ ទាក់ទិននឹងភាពត្រឹមត្រូវនិងកំហុស។ ប្រតិទិនគ្រីស្ទបរិសទ័យោងតាមកំណើតរបស់ព្រះគ្រីស្ទ។ ជនជាតិហ្វាំងឡង់ជាច្រើនជាសមាជិករបស់ព្រះវិហារ Lutheran ហេតុនេះហើយទើបគេហៅថាជាព្រះវិហារតំបន់ ។ ជនជាតិហ្វាំងឡង់ ជាច្រើនបានទទួលបុណ្យជ្រមុជទឹកជាសមាជិកព្រះវិហារ តាំងពីនៅក្មេងម្ល៉េះ ។ មនុស្សជាច្រើនរៀបអាពាហ៍ពិពាហ៍ក្នុងព្រះវិហារ។ នៅក្នុងប្រទេសហ្វាំងឡង់ គ្រូគង្វាលធ្វើពិធីបុណ្យសពសំរាប់អ្នកដែលបាត់បង់ជីវិត ។ ព្រះវិហារបានដើរតួនាទីយ៉ាងសកម្មនិងមាន ឥទ្ធិពលក្នុងសង្គម ហើយការពារផលប្រយោជន៍មនុស្សក្នុងសង្គម ។









ព្រះមានបន្ទូលតបទៅគេថា “ខ្ញុំសុំប្រាប់អោយអ្នករាល់គ្នាដឹងច្បាស់ថា គ្រប់ពេលដែលអ្នករាល់គ្នាប្រព្រឹត្តអំពើទាំងនោះ ចំពោះអ្នកតូចតាចជាងគេបំផុតម្នាក់ ដែលជាបងប្អូនរបស់យើងនេះ អ្នករាល់គ្នាក៏ដូចជាបានប្រព្រឹត្តចំពោះខ្ញុំដែរ”។ ម៉ាថាយជំពូក ទី២៥ ខ៤០









ព្រះយេស៊ូវយាងចូលមកជិតគេ ហើយមានព្រះបន្ទូលថា ខ្ញុំបានទទួលគ្រប់អំណាច ទាំងនៅលើស្ថានសួគ៌និងផែនដី ។ ដូច្នេះ ចូរនាំគ្នាចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍ អោយធ្វើជាសាវ័ក ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ម៉ាថាយជំពូក ទី២៨ ១៨_១៩

## ភាពទទួលខុសត្រូវជាអន្តរជាតិ

ភាពទទួលខុសត្រូវជាអន្តរជាតិចាប់ផ្តើមឡើងជាមួយសេចក្តីស្រឡាញ់អ្នកជិតខាងយើង។ ព្រះទ្រង់បង្កើតពិភពលោក ហើយប្រទានដល់មនុស្សលោក នូវការងារថែទាំពិភពលោក ថែទាំមនុស្សជាតិ និងបរិស្ថាន ។ ព្រះវិហារធ្វើបេសកកម្មការងារ ដែលបង្រៀនសេចក្តីជំនឿ គ្រីស្ទបរិសទ័ និងបំរើមនុស្សផ្សេងទៀត ។ គោលបំណងនៃបេសកកម្មការងារគឺផ្សព្វផ្សាយ ដំណឹងល្អទៅអោយមនុស្សទាំងអស់បានដឹង ។
ជំនួយសង្គ្រោះបន្ទាន់របស់ព្រះវិហារ ផ្តល់ជូនពេលមានវិនាសកម្មធំៗ ដូចជា គ្រោះមហន្តរាយធម្មជាតិ និងសង្គ្រាមកើតឡើងនៅជុំវិញពិភពលោក ។
ព្រះវិហារក៏ជាដៃគូក្នុងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗផងដែរ ។ សេចក្តីជំនឿរបស់គ្រីស្ទបរិសទ័ គឺជាការធ្វើទីបន្ទាល់ ជជែកវែកញែក និងសហប្រតិបត្តិការជាមួយនិកាយគ្រីស្ទបរិសទ័ផ្សេងគ្នា ។ យើងទាំងអស់គ្នា ចែកចាយសេចក្តីជំនឿដូចគ្នា ក្នុងសិរីល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

## ពិធីបុណ្យសំខាន់ៗរបស់គ្រីស្ទបរិសទ័

### បុណ្យណូអែល

នៅណូអែល ដែលជាថ្ងៃអ្នកសង្គ្រោះពិភពលោក គឺព្រះយេស៊ូវគ្រីស្ទប្រសូត ត្រូវបានប្រារព្ធឡើង ។ ណូអែលជាថ្ងៃខួបកំណើតរបស់យេស៊ូវ ។ ល្ងាចមុនណូអែល (Christmas Eve) ឬជាភាសាហ្វាំងឡង់ jouluaato គឺថ្ងៃទី២៤ ខែធ្នូ ជាពេលរៀបចំសំរាប់បុណ្យណូអែល ។ ក្នុងថ្ងៃនេះ ព្រះវិហាររៀបចំពិធីថ្វាយបង្គំព្រះ ។ បុណ្យណូអែល ២៥ ធ្នូ ជាថ្ងៃព្រះយេស៊ូវប្រសូត ហេតុនេះហើយ វាជាថ្ងៃសំរាកបុណ្យជាតិសំរាប់ហ្វាំងឡង់ ។ សំរាប់ជនជាតិហ្វាំងឡង់ បុណ្យណូអែលជាបុណ្យគ្រួសារដ៏សំខាន់បំផុត ។

### បុណ្យព្រះយេស៊ូវរស់ពីសុគត

ជាពិធីដែលព្រះយេស៊ូវមានព្រះជន្មឡើងវិញ ។ វាជាពិធីសំខាន់សំរាប់គ្រីស្ទបរិសទ័ ។ ពិធីបុណ្យនេះត្រូវបន្តដោយមួយរយៈពេលតមអាហារ អំឡុងពេលយើងត្រៀមខ្លួននៅមុខព្រះ ។ សប្តាហ៍ដែលទ្រង់រស់ពីសុគត ឬសប្តាហ៏បរិសុទ្ធ ចាប់ផ្តើមនៅថ្ងៃអាទិត្យ ។ ថ្ងៃនេះ រំលឹកយើងពេលព្រះយេស៊ូវយាងចូលក្រុងយេរូសាឡឹម ហើយប្រជារាស្ត្រចេញមកទទួលទ្រង់ក្នុងនាមជាស្តេច ដោយក្រាលស្លឹកចាក តាមផ្លូវ ។ នាថ្ងៃព្រហស្បតិ៍ យើងចងចាំអាហារពេលល្ងាចចុងក្រោយ រវាងព្រះយេស៊ូវនិងសិស្សរបស់ព្រះអង្គ ។ ការជួបជុំត្រូវបានធ្វើនៅព្រះវិហារស្ទើររៀងរាល់ថ្ងៃអាទិត្យ ។ ថ្ងៃសុក្រល្អ ជាថ្ងៃដែលព្រះយេស៊ូវសុគត ។ Easter (ជាភាសាអង់គ្លេស) ឬ pääsiäinen (ជាភាសាហ្វាំងឡង់) ជាថ្ងៃដែលព្រះអង្គរស់ពីសុគតឡើងវិញ ។ ដោយសារតែព្រះយេស៊ូវលះបង់ និងបង្ហូរព្រះលោហិតសំរាប់មនុស្ស ជាតិនេះហើយ ទើបយើងទាំងអស់គ្នាត្រូវបានសង្គ្រោះ ។

### ថ្ងៃបុណ្យទី៥០: Pentecost (ជាភាសាអង់គ្លេស) ឬ Helluntai (ជាភាសាហ្វាំងឡង់)

នៅថ្ងៃនេះ ព្រះវិញ្ញាណបរិសុទ្ធចុះមកសណ្ឋិតលើសាវក័ព្រះយេស៊ូវ ។ពួកគេចាប់ផ្តើមនិយាយប្រាប់ដោយសេចក្តីទុកចិត្តអំពីព្រះយេស៊ូវ ទៅកាន់មនុស្សទាំងឡាយ ។ ព្រះវិហារគ្រីស្ទបរិសទ័ក៏ចាប់កំណើតឡើងនាថ្ងៃបុណ្យទី៥០នេះ ។

# HYMN 501

Enoch Sontonga 1897




1. Listen, precious Father, as we pray
Help us when we come and wail to you
Here we come with pains, with heavy loads
Oh, grant blessings to the world!
Oh, grant blessings to the world!

2. Hear this humble prayer, which comes to you
It is our request for daily bread
Do not forget us, we trust in you!
Oh, grant blessings to the world!
Oh, grant blessings to the world!

3. Listen, holy Father, we need peace
All among destructions, warns and death
Give today your blessing, give your love!
Oh, grant blessings to the world!
Oh, grant blessings to the world!

4. Protect all the nature of this world
trees and forests, jungles, lands and seas
youngsters, adults, elders, every being!
Oh, grant blessings to the world!
Oh, grant blessings to the world!

5. Grant us, tender Father, faith and love
Give much joy and hope to every home
May your grace be filling all our hearts!
Oh, grant blessings to the world!
Oh, grant blessings to the world!

១_ព្រះ_វរ_បិ_តា សូម_ស្តាប់_អ_ធិ_ស្ឋាន សូម_ជួយ
កុំ_អោយ_មាន_នរ_ណា_នៅ_ឯ_កា
សូម_ទត_មើល កូន_ទ្រង់_កំ_ពុង_ឈឺ_ចាប់
ប្រ_ទាន_ពរ_ដល់_ពិភព_លោក_ទាំង_មូល (ពីរដង)

២_ព្រះ_វរ_បិ_តា_សូម_ទ្រង់_ទត_មើល_មក
កូន_ទ្រង់_ដែល_កំ_ពុង_តែ_អ_ធិ_ស្ឋាន
សូម_ប្រ_ទាន_នំ_បុ័ង_ជា_រៀង_រាល់_ថ្ងៃ
ប្រ_ទាន_ពរ_ដល់_ពិភព_លោក_ទាំងមូល (ពីរដង)

៣_ព្រះ_វរ_បិ_តា_សូម_ទ្រង់_កុំ_ភ្លេច_ឡើយ
កូន_ទ្រង់_ដែល_កំ_ពុង_ជាប់_ក្នុង_សង្គ្រាម
សូម_ប្រ_ទាន_សន្តិ_ភាព បញ្ចប់_កំ_ហឹង
ប្រ_ទាន_ពរ_ដល់_ពិភព_លោក_ទាំងមូល (ពីរដង)

៤_សូម_ទ្រង់_រក្សា និង_សូម_ប្រ_ទាន_ពរ
ដល់_ទ្វីប_អា_ហ្វ្រិក អា_មេ_រិក អឺ_រ៉ុប
ទ្វីប_អូ_ស្ត្រា_លី និង_អា_ស៊ី
ប្រ_ទាន_ពរ_ដល់_ពិភព_លោក_ទាំងមូល (ពីរដង)

ប្រសិទ្ធិពរ

សូមព្រះអម្ចាស់ប្រទានពរនិងថែរក្សាអ្នក ។ សូមព្រះអម្ចាស់ទតមកអ្នក ដោយព្រះហឫទយ័មេត្តាករុណាសូមព្រះអង្គប្រណីសណ្តោស អ្នក។ សូមព្រះអម្ចាស់សម្តែងព្រះហឫទយ័សប្បុរសចំពោះអ្នក និងប្រទានអោយអ្នកបានប្រកបដោយសេចក្តីសុខសាន្ត។ ក្នុងព្រះនាម ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ ។  ជនគណនា៦:២៤_២៦

SUOMEN EV.LUT. KIRKKO
EVANGELICAL LUTHERAN CHURCH OF FINLAND







សូមសាកសួរក្រុមជំនុំប្រចាំតំបន់របស់អ្នក បើសិនជាមានការថ្វាយបង្គំព្រះអង្គ ថ្ងៃអាទិត្យ ឬសកម្មភាពផ្សេងៗផ្តល់ជូនជាភាសាកំណើត ។ ព្រះវិហារ និងបុគ្គលិក អញ្ជើញអ្នកអោយចូលរួមក្នុងក្រុមជំនុំប្រចាំតំបន់ ឬមួយពួកគេអាចមកជួបអ្នក នៅផ្ទះរបស់អ្នក។

សូមព្រះជាម្ចាស់ប្រទានពរដល់អ្នក !